THE S.E.A. WRITE AWARD
35th



# ចន្ទ កត្តិក

ចន្ទ កត្តិក ជាបុរសម្នាក់មានរាងទាបស្រឡះ សម្បុរខ្មៅជ្រះថ្លាសទូលាយ។ មុខមាត់របស់គេ ខ្មែរមិនចំខ្មែរ ស្រែមិនចំស្រែ ក្រុងមិនចំក្រុង។ ភ្នែករបស់គេតូច មាត់របស់គេធំ។ ច្រមុះរបស់គេខ្លី ត្រចៀករបស់គេវែង។ គេគឺជាអ្នកសរសេររឿងកំប្លែងម្នាក់។ ពេលកំពុងសរសេររឿងកំប្លែង គេតែងសើចបណ្ដើរ លុះពេលណាសរសេរចប់ក៏សើចហៀរទឹកភ្នែកតែម្នាក់ឯងម្ដងទៀត។ ឱ្យតែនឹកដល់រឿងកំប្លែង គេសើចមិនឈប់។ ជួនកាលគេសើចព្រោះរឿងនោះកំប្លែងពេក។ ជួនកាលគេសើចព្រោះរឿងនោះគ្មានអ្វីកំប្លែងសោះ ក៏ដាក់ឈ្មោះថារឿងកំប្លែងដែរ។ រឿងនៅលើលោកនេះ

ស្មើរតែទាំងអស់សុទ្ធតែជារឿងកំប្លែងរបស់គេ។ គេមិនចេះ មាក់ងាយមនុស្សល្ងង់ មិនរិះគន់មនុស្សអួត មិនស្អប់មនុស្សស៊ីជោរ... ព្រោះគេយល់ថាមនុស្សទាំងអស់នេះសុទ្ធតែជាតួកំប្លែង។ គេមិនចូលចិត្តវិនិច្ឆ័យចរិតឫកពាររបស់អ្នកដទៃទេឡើយ ហើយគេចង់ឱ្យមនុស្សគ្រប់រូបមានសេរីភាព ក្នុងការរស់នៅតាមតែនិស្ស័យរៀងៗខ្លួន។

ក្រៅពីជាអ្នកនិពន្ធរឿងកំប្លែង ចន្ទ កត្តិក និយមតែងឃ្លាផ្តេសផ្តាសតាមតែនឹកឃើញ។ ថ្ងៃមួយគេបានសួរខ្លួនឯងថា តើគេគឺជាមនុស្សល្ងង់ ឬមនុស្សឆ្លាត? គេតែងគិតថា រូបគេជាមនុស្សឆ្លាតជាងអ្នកទាំងអស់ដែលនៅក្បែរខ្លួនគេ ប៉ុន្តែគេក៏ឧស្សាហ៍ឃើញមនុស្សល្ងង់ទាំងឡាយមានគំនិតដូច្នេះដែរ។ តើឱ្យគេជឿគំនិតរបស់ខ្លួនឯង ម្តេចនឹងបាន? ចន្ទ កត្តិក ស្រមៃកាលដែលគេនៅរៀន។ កាលណោះគេយល់ថា រូបគេជាមនុស្សឆ្លាតជាងគេ សោតឯគំនិតរបស់គេក៏សុទ្ធតែត្រឹមត្រូវ ហើយគេតែងតែប្រកែកជាមួយមិត្តរួមថ្នាក់ រកខុសរកត្រូវបែកពពុះមាត់។

នឹកឃើញរឿងនោះ គេក៏អស់សំណើច រួចនិយាយតែម្នាក់ឯងថា៖

«បើឆ្លាតជាងគេ ម៉េចក៏ប្រកែកជាមួយមនុស្សល្ងង់ទៅកើត?»

គេក៏ដឹងថា រូបគេធ្លាប់ជាមនុស្សល្ងង់ ដែលមិនដឹងថាខ្លួនឯងល្ងង់សោះ។ មនុស្សលើលោកនេះប្រហែលជាត្រូវរស់នៅក្នុងក្តីល្ងង់ខ្លៅរហូតដល់ពេលស្លាប់ទេដឹង? ពេលនោះគេក៏បានសរសេរនូវប្រយោគមួយថា៖

«មនុស្សល្ងង់មិនដែលដឹងថាខ្លួនល្ងង់ទេ ព្រោះមនុស្សដែលដឹងថាខ្លួនល្ងង់គឺជាមនុស្សឆ្លាត។»

ចន្ទ កត្តិក គឺជាមនុស្សជឿលើព្រហ្មលិខិត។ មុនពេលគេចេញពីផ្ទះ គេតែងបើកវិទ្យុស្តាប់ទំនាយជោគជតារាសីនៃឆ្នាំកំណើតរបស់គេសិន។ ថ្ងៃមួយនោះ ទំនាយឆ្នាំកំណើតរបស់គេស្រុតចុះយ៉ាងខ្លាំង ទៅធ្វើការនឹងត្រូវចៅហ្វាយស្តីបន្ទោស ហើយបើមានអ្នកណាពឹងពាក់ខ្ចីប្រាក់ កុំឱ្យគេខ្ចីឱ្យសោះ ព្រោះគេនឹងស៊ីដាច់។ ស្តាប់ឮអ៊ីចឹង គេតាំងចិត្តថា ថ្ងៃនេះត្រូវរៀបចំឫកពាឱ្យល្អ កុំឱ្យចៅហ្វាយស្តីបន្ទោសបាន ហើយបើមានអ្នកណាមកខ្ចីលុយ គេមិនព្រមឱ្យជាដាច់ខាត។

នាឡិកាដៃរបស់ ចន្ទ កត្តិក ចង្អុលម៉ោងប្រាំបី។ គេក៏ទៅធ្វើការ។ ដើម្បីធ្វើខ្លួនជាមនុស្សដើរលឿនជាងពេលវេលា គេបានកម្រិតម៉ោងនាឡិកាដៃរបស់ខ្លួនឱ្យដើរលឿនប្រាំបួននាទី។ ប៉ុន្តែដដែលនៅដដែល ព្រោះតែគេដឹងច្បាស់ថាម៉ោងរបស់គេដើរលឿនប្រាំបួននាទី គេក៏ប្រើពេលវេលាយឺតប្រាំបួននាទីវិញ។

ពេលមកដល់កន្លែងធ្វើការ ចន្ទ កត្តិក ខំញញឹមញញែម តាំងពីចម្ងាយដាក់ចៅហ្វាយ។ ចៅហ្វាយស្រីរបស់គេឈ្មោះ ព្រហ្ម ស៊ីណែត មានរាងវែងដូចជាទូកង ភ្នែកធំដូចជាភ្នែកមៀម រោមចិញ្ចើមងដូចជាកន្ទុយខ្ទួយ មាត់ស្រួចដូចជាមាត់ចាប ឯច្រមុះគ្មានអ្វីគួរឱ្យកត់សំគាល់ទេ។ ឃើញឫកពាចម្លែករបស់គេ ចៅហ្វាយស្រីធ្វើភ្នែកស្លឹ រួចសួរទៅគេថា៖

«យ៉ាងម៉េច? ថ្ងៃនេះលេបថ្នាំច្រឡំអ្ហេះ?»

ចន្ទ កត្តិក ញញឹមឱនលំទោន តបទៅចៅហ្វាយស្រីវិញ៖

«បាទ! ថ្ងៃនេះខ្ញុំអត់លេបថ្នាំទេចៅហ្វាយ។»

ចៅហ្វាយស្រីពេបមាត់តាមទម្លាប់អាក្រក់របស់គាត់ ទើបបង្ហើយសម្ដីខ្លួន៖

«មើលទៅដូចជាមានក្ដីសុខណាស់ហ្ន៎!»

ចន្ទ កត្តិក ឆ្លើយតបយ៉ាងទន់ភ្លន់៖

«បាទ...ចៅហ្វាយស្រី...!»

ចៅហ្វាយស្រី ព្រហ្ម ស៊ីណែត សម្លក់គេ រួចដើរប៉ាត់រញ៉ាត់ចេញទៅ ទើបគេក្រឡាស់ឃ្លាចុងក្រោយរបស់គេ រួចសើចរលាក់ដូចរលកទឹក ហើយដើរលបៗទៅតុធ្វើការរបស់ខ្លួន។

មួយស្របក់ក្រោយក៏ឃើញមិត្តរួមការងាររបស់ ចន្ទ កត្តិក ម្នាក់ដើរចូលមករកគេ។ គេម្នាក់នោះឈ្មោះ សោម ពីផល រូបរាង

មុខមាត់ស្រដៀងសត្វស្វា និងទុកពុកចង្កាដូចសត្វពពែ។ សោម ពីផល បន្លឺមកកាន់គេថា៖

«ចន្ទ កត្តិក! ឱ្យគ្នាខ្ចីលុយខ្លះមក! គ្នាត្រូវការបន្ទាន់ណាស់!»

ចន្ទ កត្តិក បុកពោះភឹបៗ គិតតែក្នុងចិត្ត៖

«វីវរហើយ! ជាមួយចៅហ្វាយគ្រាន់តែស្តីឱ្យទេ តែអានេះប្រុងបោកយកលុយស្រស់ៗតែម្តង! គិតយ៉ាងម៉េចអីចេះ?»

«យ៉ាងម៉េច? គ្រាន់តែពឹងពាក់ប៉ុណ្ណឹង គិតភ្លឹកទៅឋានលើសួរព្រះឥន្ទសិនអ្ហ៎?»

ចន្ទ កត្តិក ឆ្លើយទាំងញ័រមាត់តតាក់៖

«អត់...អត់ទេ! តែគ្នាគ្មានលុយទេ... យកទៅចូលកាកបាទក្រហមអស់ហើយ!»

សោម ពីផល អត់មាត់ថាម៉េចទេ តែបែរជាលូកយកកាបូបលុយរបស់ ចន្ទ កត្តិក មកមើល៖

«ពួកម៉ាកនឹងគ្នាអត់អ្ហ៎ា បានជាចិត្តកំណាញ់ម្ល៉េះ? លុយឱ្យពេញកាបូប ថាអត់មានលុយ! ម៉េចខ្លាចគ្នាអត់សងវិញអ្ហ?»

«យី! ម៉េចក៏ឯងដឹង?»

«មិនបាច់ចង់ដឹងថាម៉េចបានជាគ្នាដឹងទេ... ឥឡូវឱ្យខ្ចី ឬមិនឱ្យ?»

«ឱ្យ! តែ...»

សោម ពីផល កញ្ឆក់យកលុយប៉ុន្មានសន្លឹកទៅបាត់ រកតែ ចន្ទ កត្តិក ចង់ពន្យល់ប្រាប់ពីរឿងទំនាយជោគជតារាសីឱ្យដឹងមិនទាន់។ ដំបូងឡើយគេគិតថា ខ្ចីប្រាក់ប្រុងសងវិញទេ ប៉ុន្តែដល់ឃើញ ចន្ទ កត្តិក មានចិត្តចង្អៀតចង្អល់ពេក ក៏ត្រឡប់ជាគិតថា "គ្មានថ្ងៃសងលុយឯងវិញទេ អាវ៉ាអើយ!"

ចន្ទ កត្តិក ធ្វើការបណ្ដើរ គិតថាតើ សោម ពីផល ព្រមសងលុយឱ្យខ្លួនវិញឬអត់បណ្ដើរ... ស្រាប់តែចៅហ្វាយស្រី ព្រហ្មស៊ីណៃត ស្រែកចំទាលមកគេ៖

«ចន្ទ កត្តិក មកណេះឱ្យឆាប់!»

ចន្ទ កត្តិក ដើរចូលទៅជួបចៅហ្វាយស្រី ក៏ឃើញ សោម ពីផល ឈរនៅទីនោះដែរ។ គេបន្លឺទៅកាន់ចៅហ្វាយស្រី ដែលកំពុងតែសម្លក់ត្លែមករកខ្លួន៖

«មានការអ្វីហៅខ្ញុំអ្ហះចៅហ្វាយ?»

ចៅហ្វាយស្រីក៏បួញមាត់ស្ដីថា៖

«តើម្សិលមិញលោកឯងទៅសណ្ឋាគារស្ទឹងលាបធ្វើអី?»

«អ្ហាំ! ម៉េចក៏ចៅហ្វាយដឹង?»

«សោម ពីផល ជាអ្នកប្រាប់។ លោកឯងដឹងទេ? ដោយសារតែលោកឯងដើរចោលការិយាល័យ ទើបធ្វើឱ្យចោរចូលមកលួចរូបថតសង្សារសំណព្វចិត្តរបស់ខ្ញុំបាត់។»

«ក្រែងម្សិលមិញ សោម ពីផល នៅការិយាល័យទេតើ?»

«គេនៅមែនហើយ តែគេឈឺពោះសំងំដេកលក់មួយស្របក់...»

ចន្ទ កត្តិក សម្លឹងមើលមុខ សោម ពីផល ។ គេនឹកក្នុងចិត្តថា កោតតែចៅហ្វាយស្រី ព្រហ្ម ស៊ុំណែត នេះល្ងង់ ជឿថាមនុស្សឈឺពោះ អាចសំងំដេកលក់បាន? កាលពីម្សិលមិញ ចន្ទ កត្តិក ទៅសណ្ឋាគារស្ទឹងលាប ជួបលោក ឡុង សារ័ត្ន ព្រោះតែយកឯកសារមួយទៅជូនគាត់ជំនួស សោម ពីផល ដែលត្អូញថាឈឺពោះខ្លាំង ទៅខ្លួនឯងមិនកើត។ ដល់ឥឡូវ សោម ពីផល ឆ្លើយយកតែរួចខ្លួន ធ្វើបាបឱ្យគេទទួលទោសតែម្នាក់ឯងទៅវិញ។ ចិត្តមួយគិតថា នឹងនិយាយការពិតឱ្យមានទោសទាំងពីរនាក់ ប៉ុន្តែចិត្តមួយទៀតគិតថា បើធ្វើអ៊ីចឹងដូចជាគ្មានបានប្រយោជន៍អីផង។ គិតរួច គេមិននៅបកស្រាយប្រាប់ចៅហ្វាយស្រីល្ងង់ឱ្យខាតទឹកមាត់ទេ ហើយក៏ដើរចេញវិញ ប្រញាប់មកសរសេរប្រយោគមួយថា៖

«បើខ្ញុំទទួលទោសអាចធ្វើឱ្យគេសប្បាយចិត្ត ខ្ញុំសុខចិត្តទទួលទោសនោះ?»

អង្គុយទ្រឹងគិតមួយភ្លែត គេក៏សរសេរពាក្យមួយប្រយោគទៀតថា៖

«គេចង់សប្បាយចិត្តលើគំនរទុក្ខរបស់អ្នកដទៃ តែខ្ញុំព្រមកើតទុក្ខលើភ្នំរីករាយរបស់អ្នកដទៃ។»

សកម្មភាពដ៏ចម្លែករបស់ ចន្ទ កត្តិក ធ្វើឱ្យចៅហ្វាយស្រី ព្រហ្ម ស៊ីណែត និង សោម ពីផល កើតក្ដីងឿងឆ្ងល់ពន់ពេក។ ទាំងពីរនាក់នាំគ្នាមកលបមើលគេ រួចនិយាយប្រាប់គ្នាថា៖

«ចន្ទ កត្តិក ប្រហែលជាជិតឆ្កួតហើយ!»

ចន្ទ កត្តិក រស់នៅក្នុងពិភពលោកនេះដូចគេឯង ហើយមានរបៀបរស់នៅម៉្យាងរបស់ខ្លួន។

*កក្កដា ២០០៧*